# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC | Meet the Business Owner Who Received a Loan Guaranteed by CGCC

**លោកស្រី ខៀវ ធិតា ស្ថាបនិក SOGE Green Solar Energy | Ms. Kheav Thida, Founder of SOGE Green Solar Energy Cambodia**

KH Solar Green Energy (SOGE) គឺជាក្រុមហ៊ុនផ្គត់ផ្គង់ថាមពលបៃតង ដោយប្រើប្រាស់ថាមពលនៃពន្លឺព្រះអាទិត្យ ដើម្បីស្រូបយកទឹកទន្លេធម្មជាតិ សម្រាប់ការស្រោចស្រប់ដំណាំរបស់ប្រជាកសិករខ្មែរ  ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០៨។ បន្ទាប់ពីចាប់ផ្តើមដំណើរការបានមួយរយៈ អតិថិជនចាប់ផ្តើមស្គាល់ក្រុមហ៊ុន និងចាប់ផ្តើមផ្តល់ការជឿទុកចិត្តលើសេវាកម្មរបស់ពួកយើង។ នាងខ្ញុំបានមើលឃើញពីឱកាស ក្នុងការពង្រីកអាជីវកម្មនេះឱ្យកាន់តែធំ។ ពួកយើងមានបច្ចេកវិទ្យាគ្រប់គ្រាន់ ប៉ុន្តែខ្វះធនធានមនុស្ស និងទុនបន្ថែម។

នាងខ្ញុំបានប្រឹក្សាជាមួយធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួន ដើម្បីទទួលបានទុនបន្ថែម។ ដោយសារនាងខ្ញុំខ្វះទ្រព្យធានា ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ក៏បានណែនាំនាងខ្ញុំ អំពីការធានាឥណទានលើកម្ចីអាជីវកម្មរបស់ CGCC ដែលអាចផ្តល់ការធានាលើកម្ចីរបស់នាងខ្ញុំ ដើម្បីឱ្យធនាគារអាចផ្តល់កម្ចីដល់នាងខ្ញុំបាន ទោះបីគ្មានទ្រព្យធានា។ ដោយសារការធានាឥណទានពី CGCC នាងខ្ញុំអាចទទួលបានទុនបន្ថែម ដើម្បីសាងសង់ស្ថានីយបូមទឹកថ្មីៗទៀតបន្ថែម។

SOGE បានប្រើប្រាស់កម្ចីដែលមានដែលការធានាពី CGCC ដើម្បីពង្រីកការសាងសង់ស្ថានីយ៍បូមទឹក នៅតាមបណ្តាខេត្ត មួយចំនួនដូចជា ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ។ ស្ថានីយ៍ទាំងអស់នោះ អាចស្រោចស្រព្វផ្ទៃដីប្រម៉ាណ ១៦០០ ហិកតា និងបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ១០០០ គ្រួសារ។

នាងខ្ញុំយល់ថា ការធានាឥណទានរបស់ CGCC ពិតជាអាចគាំទ្រដល់អាជីវកម្មរបស់នាងខ្ញុំ  ក៏ដូចជាសហគ្រាសខ្នាតតូច  និងមធ្យមផ្សេងទៀត  ដែលមានសក្តានុពល  ប៉ុន្តែខ្វះទ្រព្យធានា  ឱ្យទទួលបានទុនបន្ថែមចាំបាច់ពីធនាគារ  ឬគ្រឹះស្ថានហិរញ្ញវត្ថុ សម្រាប់ការពង្រីកអាជីវកម្ម៕




EN Solar Green Energy (SOGE), established in 2008, is a company providing green energy solutions using solar energy to irrigate the crops of Cambodian farmers. Shortly after the establishment, customers began to recognize SOGE and trust our services. I saw the opportunity to expand our business. We have the technology but lack human resources and capital.

I consulted with some banks and microfinance institutions to get additional capital. Because I didn't have enough collateral for the loans, J Trust Royal Bank introduced me CGCC's credit guarantee service which can guarantee my loan so that the bank can lend me without requiring my collateral. With the credit guarantee, I could get additional capital to build new pumping stations.

SOGE used the loans guaranteed by CGCC to expand the construction of pumping stations in some provinces such as Pursat, Kampong Cham, Kampong Chhnang and Kampong Thom. The stations can irrigate about 1,600 hectares and benefit about 1,000 families.

I think that CGCC's credit guarantees can really support my business as well as other potential SMEs that lack collateral to get necessary capital from banks or microfinance institutions for their business expansion.

